# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២១ ខែ មិនា ឆ្នាំ២០១៣

## ជប៉ុនផ្តល់ ២២២,៥១១ ដុល្លារអាមេរិក សម្រាប់គម្រោងប្រព័ន្ធចម្រោះទឹកស្អាត ផ្ទះកុមារ និងអគារសិក្សា



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយ ឧបត្ថម្ភ ឥតសំណង សម្រាប់ គម្រោង ទ្រង់ទ្រាយ តូច សន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន២២២,៥១១ដុល្លាអាមេរិកដល់ស្ថាប័នទទួលជំនួយចំនួន៣។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខា នៅថ្ងៃនេះ ដោយ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង តំណាងស្ថាប័នទទួលជំនួយទាំង៣សម្រាប់គម្រោងដូចតទៅ៖

<u>១. គម្រោងតំឡើងប្រព័ន្ធចម្រោះទឹកស្អាតក្នុងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ (១០០,៧៤៥ដុល្លាអាមេរិក)</u>

<u>ស្ថាប័នទទួលជំនួយ៖ សម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ</u>

គម្រោងនេះគឺដើម្បីតំឡើងប្រព័ន្ធចម្រោះទឹកស្អាតខ្នាតធំមួយដែលអាចចម្រោះទឹកបាន ៧,០០០លីត្រក្នុងមួយថ្ងៃនៅក្នុងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ ជាមួយនឹងគម្រោងនេះ យើងសង្ឃឹមថា ប្រជាពលរដ្ឋប្រមាណ១១,៥០០នាក់នឹងរីករាយជាមួយការទទួលទានទឹកស្អាតដែលអាចជៀសវាងបញ្ហាសុខភាពក្នុងសហគមន៍។



ស្ថានីយ៍ចម្រោះទឹកដែលគ្រោងនឹងសាងសង់ នឹងបូមទឹកពីស្រះដែលនៅក្រោយសាលាស្រុក

<u>២. គម្រោងសាងសង់ផ្ទះកុមារក្នុងឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ (៤០,៦៦៦ដុល្លាអាមេរិក)</u>

<u>ស្ថាប័នទទួលជំនួយ៖ មជ្ឈមណ្ឌលដើម្បីអភិវឌ្ឍន៍</u>

គម្រោងនេះគឺដើម្បីសាងសង់អគារផ្ទះកុមារមួយខ្នងដែលមានពីរបន្ទប់ ក្នុងគោលបំណងផ្តល់ការអប់រំកាន់តែប្រសើរដល់កុមារ ប្រមាណ១៤០ នាក់ ដែលមានអាយុពី ៣ ទៅ ៥ ឆ្នាំ ក្នុងឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ ជាផ្នែកមួយក្នុងគម្រោងនេះដែរ បរិក្ខារអនាម័យក៏នឹងត្រូវសាងសង់ផងដែរ។



សាលប្រជុំក្នុងភូមិដែលកំពុងត្រូវបានប្រើប្រាស់ជាផ្ទះកុមារ

<u>៣. គម្រោងសាងសង់អគារសិក្សាក្នុងសាលាបឋមសិក្សាចោងម៉ោង ខេត្តកំពង់ឆ្នាំង (៨១,១០០ដុល្លាអាមេរិក)</u>

<u>ស្ថាប័នទទួលជំនួយ៖ ក្រុមប្រឹក្សាឃុំចោងម៉ាង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង</u>

គម្រោងនេះគឺដើម្បីសាងសង់អគារសិក្សាមួយខ្នងមាន៥បន្ទប់ដោយមានបំពាក់សង្ហារឹម និងបរិក្ខារអនាម័យសម្រាប់សាលាបឋមសិក្សាចោងម៉ាង ក្នុងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ ជាមួយនឹងគម្រោងនេះ សិស្សានុសិស្ស ប្រមាណ ២៩២នាក់ នឹងរីករាយជាមួយការសិក្សាក្នុងបរិស្ថានអប់រំដែលកាន់តែប្រសើរឡើង។



អគារសិក្សាចាស់ដែលស្ទើតែប្រើលែងបាន

ជំនួយ *គូសាណូណិ* របស់ រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍និងស្ថាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជុំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៤៩.១លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួ ន៤៩១ គម្រោងនៅទូទាំងប្រទេស។



---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីមែល:* *eco.jpn@.pp.mofa.go.jp*
*គេហទំព័រ:* *http://www.kh.emb-japan.go.jp*